# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

អអក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ៨៤ /សណភ-ភប អអក

ភ្នំពេញ, ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# ស្តីពីការប្រកាសបញ្ចុះអត្រាថ្លៃលក់អគ្គិសនី នៅផ្នែកខ្លះនៃស្រុកកោះកុង ស្រុកថ្មបាំង ស្រុកមណ្ឌលសីមា និងស្រុកគីរីសាគរ ខេត្តកោះកុង ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករ ផាត សុធា

<u>យោង</u>៖ - ការតភ្ជាប់យកប្រភពអគ្គិសនីពីអគ្គិសនីកម្ពុជា នៅចុងខែធ្នូ ឆ្នាំ២០១៥

- អាជ្ញាប័ណ្ណចែកចាយរបស់សេវាករ ផាត សុធា លេខ៣៧០.អ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣
- ការពិនិត្យគណនាថ្លៃដើម និងថ្លៃលក់ក្រោយការតភ្ជាប់ប្រភពថ្មីរបស់នាយកដ្ឋានបញ្ជីថ្លៃលក់នៃអាជ្ញាធរអគ្គិសនីកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូនសាធារណជន **អ្នកប្រើប្រាស់អគ្គិសនីក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនី** របស់សេវាករឈ្មោះ ផាត សុធា ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីនៅផ្នែកខ្លះនៃស្រុកកោះកុង ខេត្តកោះកុង មេត្តាជ្រាបថា លើមូលដ្ឋាននៃយុទ្ធសាស្ត្រពង្រីកប្រភពអគ្គិសនីដែលមានថ្លៃថោកចេញពីអនុស្ថានីយបណ្តាញជាតិ **អគ្គិសនីកម្ពុជា** បានធ្វើការវិនិយោគពង្រីកខ្សែបណ្តាញបញ្ជូនវងអគ្គិសនី ៣៥ kV បញ្ជូនប្រភពអគ្គិសនីទៅផ្គត់ផ្គង់ឲ្យតំបន់អាជ្ញាប័ណ្ណចែកចាយរបស់សេវាករ ផាត សុធា ក្នុងតំណាក់កាលដំបូងនៅឃុំតាតៃក្រោម និងឃុំត្រពាំងរ៉ូង ស្រុកកោះកុង ដែលកំពុងប្រើម៉ាស៊ីនម៉ាស៊ូតដៀសែលផលិតអគ្គិសនី រួចបន្តទៅភូមិ ឃុំ ស្រុក ជាប់គ្នាជាបន្តបន្ទាប់ ដើម្បីអាចបន្ថយអត្រាថ្លៃលក់បច្ចុប្បន្ន ឲ្យថយចុះជាបន្តបន្ទាប់សម្រួលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ជាមួយគ្នានឹងការវិនិយោគរបស់អគ្គិសនីកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា ក៏បានជម្រុញឱ្យសេវាករ ផាត សុធា ត្រៀមរៀបចំប្រព័ន្ធតភ្ជាប់ និងពង្រីកបណ្តាញចែកចាយទៅគ្រប់ភូមិទាំងអស់ដែលនៅសល់ ក្នុងតំបន់អាជ្ញាប័ណ្ណរបស់ខ្លួន។ តាមការពិនិត្យ វិភាគថ្លៃដើមអគ្គិសនីនៅតំបន់របស់សេវាករ ផាត សុធា ឡើងវិញ ក្នុងសេណារីយ៉ូមានប្រភពអគ្គិសនីថោកដំបូង ស្របតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ឃើញថា ថ្លៃដើមនៅមានកម្រិត ព្រោះទំហំទីផ្សារលក់ថាមពលរបស់សេវាករនៅតូច ធៀបនឹងទុនវិនិយោគ និងត្រូវប្រើប្រាស់ទុនថែមទៀត ដើម្បីកែលម្អឲ្យបានត្រឹមត្រូវតាមស្តង់ដារបច្ចេកទេសកំណត់ និងពង្រីកបណ្តាញចែកចាយបន្ថែម។

យោងតាមការគណនាថ្លៃលក់តាមថ្លៃប្រភពថ្មីនេះ អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេច និងអនុញ្ញាតឱ្យសេវាករឈ្មោះ ផាត សុធា ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីនៅផ្នែកខ្លះនៃស្រុកកោះកុង និងស្រុកមណ្ឌលសីមា

ខេត្តកោះកុង បញ្ចុះអត្រាថ្លៃលក់បច្ចុប្បន្ន ពី ៣,១០០ រៀល/គីឡូវ៉ាត់ម៉ោង មកអត្រាថ្លៃលក់ថ្មី ស្មើ ១,000 រៀល/គីឡូវ៉ាត់ម៉ោង គិតលើថាមពលប្រើប្រាស់ ចាប់ពីខែមករា ឆ្នាំ២០១៦ រហូតខែមីនា ឆ្នាំ២០១៦ ។ អត្រាថ្លៃលក់ក្រោយខែមីនា ឆ្នាំ២០១៦ អាជ្ញាធរអគ្គិសនីកម្ពុជា នឹងកំណត់ឡើងវិញ តាមផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់របស់រាជរដ្ឋាភិបាល។

អាស្រ័យហេតុនេះ សូមអ្នកប្រើប្រាស់អគ្គិសនី អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករឈ្មោះ ផាត សុធា មេត្តាជ្រាបជាពត៌មាន និងអនុវត្តឲ្យមានប្រសិទ្ធភាព។ ៗ

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

ចម្លងជូន ៖

- ក្រសួងរ៉ែ និងថាមពល
- សាលាខេត្តកោះកុង
- មន្ទីររ៉ែ និងថាមពល ខេត្តកោះកុង
- សាលាស្រុកកោះកុង
- សាលាស្រុកមណ្ឌលសីមា
- សាលាស្រុកគីរីសាគរ
- សាលាស្រុកថ្មបាំង
- សាលាឃុំតាតៃក្រោម
- សាលាពារ៉ែត្រពាំងរូង
- សាលាឃុំទួលគគី
- សាលាកោះកាពិ
- សាលាឃុំជ្រោយប្រស់
- សាលាឃុំព្រែកខ្សាច់
- សាលាឃុំភ្ញីមាស
  "ដើម្បីជូនជ្រាប"
- សេវាករ ផាត សុធា
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh